**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គនាយកដ្ឋានកសិកម្ម**

លេខ.....៣៧៤.....អ.ន.ក

ថ្ងៃសុក្រ ១៣កើត.....ខែចេត្រ.....ឆ្នាំច សំរឹទ្ធិស័ក.....ព.ស.២៥៦១...
រាជធានីភ្នំពេញ ថ្ងៃទី..៣០.....ខែ..មីនា.......ឆ្នាំ២០១៨.

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ៖** របាយការណ៍ស្ដីពីសកម្មភាពអនុវត្តការងារប្រចាំត្រីមាសទី១ ឆ្នាំ២០១៨ របស់អគ្គនាយកដ្ឋានកសិកម្ម។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតរាយការណ៍ជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាប នូវលទ្ធផលអនុវត្តសកម្មភាពការងាររបស់អគ្គនាយកដ្ឋានកសិកម្មប្រចាំត្រីមាសទី១ ឆ្នាំ២០១៨ មានដូចខាងក្រោម៖

I. **លទ្ធផលបង្កបង្កើនផលកសិកម្មរដូវប្រាំងឆ្នាំ២០១៧-២០១៨** (គិតត្រឹមថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨)

**១. ដំណាំស្រូវ** : ផ្ទៃដីស្ទូងព្រោះសរុបអនុវត្តបានចំនួន ៥៥០.៧៩៩ ហ.ត ស្មើនឹង១២៤,១៤% នៃផែនការ ចំនួន ៤៤៣.៧០០ ហ.ត លឿនជាងឆ្នាំមុនចំនួន ៣២.០៧០ ហ.ត

- ការងារភ្ជួររាស់ដី : ផ្ទៃដីភ្ជួររាស់សរុបអនុវត្តបានចំនួន ៥៦៣.១០៩ ហ.ត យឺតជាងឆ្នាំមុនចំនួន ១.៣៣៤ ហ.ត ក្នុងនោះផ្ទៃដីភ្ជួររាស់ដោយគ្រឿងយន្តចំនួន ៥៥០.៨៣២ ហ.ត ស្មើនឹង៩៧,៨១%
- ផ្ទៃដីសាបសរុប : ៤៧៩ ហ.ត យឺតជាងឆ្នាំមុនចំនួន ៧៧ ហ.ត
- ការងារប្រមូលផលស្រូវរដូវប្រាំងឆ្នាំ២០១៧-២០១៨ : នៅក្នុងត្រីមាសទី១នេះ ការងារប្រមូលផលស្រូវរដូវប្រាំងសម្រេចបានលើផ្ទៃដី ៣៨១.២៥១ ហ.ត ស្មើនឹង៦៩,២២% នៃផ្ទៃដីអនុវត្ត ដែលទទួលបានទិន្នផលមធ្យម ៤,៤២៨ តោន/ហ.ត និងបរិមាណផលសរុប ១.៦៨៨.០៩៥ តោន។ មានខេត្តចំនួនពីរដែលបានបញ្ចប់ការងារប្រមូលគឺខេត្តបាត់ដំបង និងខេត្តកំពង់ចាម ។







*ក្រាហ្វិក៖ ស្ថិតិផ្ទៃដីភ្ជួររាស់ និងដាំដុះស្រូវរដូវប្រាំងពីឆ្នាំ២០១៤-២០១៨ គិតត្រឹម ត្រីមាសទី១នៃឆ្នាំ*

តាមក្រាហ្វិកខាងលើបង្ហាញថា ក្នុងរយៈពេល៥ឆ្នាំដូចគ្នាគិតត្រឹមត្រីមាសទី១ ផ្ទៃដីភ្ជួររាស់រដូវប្រាំងឆ្នាំ ២០១៨ មានចំនួនច្រើនជាងឆ្នាំ២០១៤ និងឆ្នាំ២០១៦ ប៉ុន្តែតិចជាងឆ្នាំ២០១៥ និងឆ្នាំ២០១៧។ ដោយឡែក ការងារដាំដុះស្រូវរដូវប្រាំងឆ្នាំ២០១៨នេះ មានចំនួនច្រើនជាងបណ្ដាឆ្នាំមុនៗ បើប្រៀបធៀបរយៈពេលដូចគ្នា៥ឆ្នាំ ចុងក្រោយ។



អាសយដ្ឋានលេខ: ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ:(០២៣) ៨៨៣ ៤២៧ ទូរសារលេខ:(០២៣) ៨៨៣ ៤២៧
Address # 54B/49F, Street 395-656, Sangkat Toeuk Laak 3, Khan Tuol Kok, Phnom Penh. Cambodia, Phone : (023) 883 427, Fax : (023) 883 427